## គោលដៅយោធា (military objective)

គោលដៅយោធា សំដៅដល់មនុស្ស ឬវត្ថុ ដែលអាចរងនូវការវាយប្រហារ ដោយស្របច្បាប់ក្នុងជម្លោះប្រដាប់អាវុធ។ មនុស្ស រាប់បញ្ចូលអ្នកប្រយុទ្ធ (combatant) ឬ ជនស៊ីវិលដែលចូលរួមដោយផ្ទាល់ក្នុងជម្លោះប្រដាប់អាវុធ ([civilian](civilian))។ អ្នកប្រយុទ្ធ ត្រូវបានគេវាយប្រហារ នាពេលណាក៏បាន ទោះបីក្នុងអំឡុងពេលសម្រាក ដូចជាកំពុង ដេក ឬហូបអាហារ។ ក្នុងសង្គ្រាមក្នុងស្រុក អ្នកវាយប្រយុទ្ធ (fighter) ត្រូវបានចាត់ចូលជាគោលដៅយោធា និងអាចរងនូវការវាយប្រហារផងដែរ។

សម្រាប់ជនស៊ីវិល ក្នុងសង្គ្រាមក្នុងស្រុក (non-international armed conflict) ពួកគេអាចជាគោលដៅនៃការវាយប្រហារ នៅក្នុងអំឡុងពេល ពួកគេចូលរួមដោយផ្ទាល់ក្នុងអរិភាព។ ពាក្យ «ចូលរួមដោយផ្ទាល់» ត្រូវបានស្នើឲ្យបកស្រាយចង្អៀត ក្នុងន័យថា ការចូលរួមត្រូវ បង្ហាញពីចំណងហេតុផលផ្ទាល់ រវាងសកម្មភាពចូលរួម និង ហានិភ័យ កើតមានចំពោះសត្រូវ នៅក្នុងទីកន្លែង និងពេលវេលាដែលហេតុការណ៍នោះបានកើតឡើង។

វត្ថុ ត្រូវតែមានចរិតផ្នែកយោធាដោយពិចារណា លើទីតាំង ឬគោលបំណងនៃវត្ថុ មានប្រកបដោយប្រសិទ្ធភាព ដល់សកម្មភាពយោធា ហើយដែលការបំផ្លាញវត្ថុនោះ ដោយផ្នែក ឬទាំងស្រុង នឹងប៉ះពាល់ដល់ផលប្រយោជន៍យោធា (មាត្រា ៥២.២ នៃ AP I)។ ប្រព័ន្ធដឹកជញ្ជូន ទីតាំងប្រេងឥន្ធនៈ ទីតាំងផលិតអាវុធ មពលជាដើម ជាគោលការណ៍យោធា (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 419-420)។